ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករគណនេយ្យនិងសវនកម្ម

លេខ..០៤០/.......ន.គ.ស/គ.ល.៣./២៥

ថ្ងៃអង្គារ ៤ កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ធ្នូ គ.ស.២០២៥

# សេចក្តីជូនដំណឹង

## ស្តីពី

## កាតព្វកិច្ចនៃការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៥ មកនិយ័តករគណនេយ្យនិងសវនកម្ម

និយ័តករគណនេយ្យនិងសវនកម្ម (ន.គ.ស.) នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) មានកិត្តិយស សូមជម្រាបជូនដល់ ម្ចាស់សហគ្រាស និងប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញ ជ្រាបថា៖ អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធ សហគ្រាស និងអង្គភាពមិនស្វែងរកប្រាក់ចំណេញ ហៅកាត់ថា (អង្គភាព) ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៥ ស្របតាមស្តង់ដាគណនេយ្យជាធរមាន មក ន.គ.ស. តាមពេលវេលាដូចខាងក្រោម៖

១. <u>សហគ្រាស និងអង្គភាព ដែលមិនរងសវនកម្មឯករាជ្យ</u> ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក ន.គ.ស. **មិនឱ្យហួសថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៦។** សហគ្រាស និងអង្គភាព ដែលទទួលបានការអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក ន.គ.ស. មិនឱ្យហួសរយៈពេល **៣ខែ និង២០ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

២. <u>សហគ្រាស និងអង្គភាព ដែលរងសវនកម្មឯករាជ្យ</u> ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មរួចមក ន.គ.ស. **មិនឱ្យហួសថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៦។** សហគ្រាស និងអង្គភាព ដែលទទួលបានការអនុញ្ញាតឱ្យបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក ន.គ.ស. មិនឱ្យហួសរយៈពេល **៦ខែ និង២០ថ្ងៃ** គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

**ជាមួយគ្នានេះ ដើម្បីជួយដល់សហគ្រាស និងអង្គភាព អនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មបានត្រឹមត្រូវ ជៀសផុតពីការទទួលរងពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ន.គ.ស.សូមរំលឹកអំពីកាតព្វកិច្ចស្នូលមួយចំនួនដែលសហគ្រាស និងអង្គភាព ត្រូវអនុវត្តដូចខាងក្រោម៖**

១. ត្រូវកាន់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ។

២. ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាមស្តង់ដាគណនេយ្យជាធរមាន ឱ្យបានរួចរាល់ក្នុងរយៈពេល ៣ខែ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

៣. ដើម្បីលើកកម្ពស់កម្រិតអនុលោមភាព និងមានភាពងាយស្រួលក្នុងការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រព័ន្ធ E-Filing សហគ្រាសធុនតូច និងមធ្យម ដែលមិនមែនជាសហគ្រាសរងសវនកម្មឯករាជ្យ និងមិនមែនជាសហគ្រាសទទួលខុសត្រូវជាសាធារណៈ ត្រូវប្រើក្របខណ្ឌកាត់បន្ថយការរាយការណ៍ហិរញ្ញវត្ថុ-កម្ពុជា, ថ្នាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុឌីជីថល និងមាតិកាគណនីនៃប្លង់គណនេយ្យសម្រាប់សហគ្រាស។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
គេហទំព័រ : www.acar.gov.kh
ទូរស័ព្ទ ០៨៥ - ២៣ ៨៨២ ១១១
Phone: 023 882 111
អ៊ីមែល : info@acar.gov.kh

៤. ត្រូវបញ្ចប់ការងារសវនកម្មឯករាជ្យ និងបោះផ្សាយមតិសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនឱ្យហួស រយៈពេល ៦ខែ គិតចាប់ពីកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ប្រសិនបើសហគ្រាស ឬអង្គភាព នោះជាប់កាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ។

៥. សហគ្រាស ឬអង្គភាព ដែលមិនទាន់មានលេខអត្តសញ្ញាណកម្មរបាយការណ៍ហិរញ្ញវត្ថុ (FIN) ត្រូវស្នើសុំលេខ FIN ពី ន.គ.ស. ដោយអាចអនុវត្តតាមសៀវភៅណែនាំអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុ (ទាញយកតាមរយៈ QR ខាងក្រោម)។

៦. សហគ្រាស ឬអង្គភាព ដែលបានប្រែប្រួលការចាត់ថ្នាក់ទៅជា **រងសវនកម្មឯករាជ្យ** ឬ **មិនរងសវនកម្មឯករាជ្យ** ត្រូវដាក់លិខិតស្នើសុំផ្លាស់ប្តូរលេខ FIN មក ន.គ.ស. ឱ្យបានមុន ៦០ថ្ងៃ នៃកាលបរិច្ឆេទផុតកំណត់ដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុ។

៧. សហគ្រាស ឬ អង្គភាព អាចចាត់តាំងអ្នកតំណាងដើម្បីបំពេញកាតព្វកិច្ចគណនេយ្យនិងសវនកម្មជាមួយ មន្ត្រី ន.គ.ស. ដោយតំណាងអាចជាបុគ្គលិករបស់សហគ្រាស ឬ អង្គភាពផ្ទាល់ ឬ ជាក្រុមហ៊ុនគណនេយ្យ ឬក្រុមហ៊ុនសវនកម្ម ដែលមានអាជ្ញាបណ្ណនៅមានសុពលភាពពី ន.គ.ស. ដូចមានក្នុងបញ្ជីភ្ជាប់មកជាមួយនឹងសេចក្តីជូនដំណឹងនេះ។ ម្ចាស់សហគ្រាស ឬ ប្រធានអង្គភាព ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះរាល់សកម្មភាពរបស់អ្នកតំណាងរបស់ខ្លួន។ ក្នុងករណីអ្នកតំណាងជាក្រុមហ៊ុនគណនេយ្យ ឬក្រុមហ៊ុនសវនកម្ម ត្រូវមានលិខិតផ្ទេរសិទ្ធិពីម្ចាស់សហគ្រាស ឬ ប្រធានអង្គភាព។

៨. សហគ្រាស ឬអង្គភាព ត្រូវបង់កម្រៃសេវាសាធារណៈ ស្របតាមប្រកាសលេខ ០០២ អ.ស.ហ. ប្រ.ក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៥ ស្តីពី សេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងមន្ត្រីរបស់ ន.គ.ស. តាមរយៈប្រព័ន្ធតេឡេក្រាមដូចខាងក្រោម៖

- សហគ្រាសរងសវនកម្មឯករាជ្យ ៖០៩៦ ៩ ១៩៩ ៩៩៨/០១៦ ៥៩៨ ៣៨៦/០៧៧ ៨០៥ ៥៥២/០៧០ ២៣៣ ២៧៨
- សហគ្រាសមិនរងសវនកម្មឯករាជ្យ ៖០៨១ ៦៤៤ ៦៦៣/០៨៥ ៣៩៤ ៩៣៩/០១០ ៦៥៤ ៣៨៧/០៩២ ៦៨៨ ២៩៧
- អង្គភាពមិនស្វែងរកប្រាក់ចំណេញ ៖០៨៥ ៤៤៤៤ ៨៨/០៨៥ ៩០៤ ៨៤៨/០១០ ៥៤៩ ៩៨៧/០៨៩ ៨១៨ ៧១៧/០៧០ ២១២ ២៣៦

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមម្ចាស់សហគ្រាស និង ប្រធានអង្គភាព ជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាព និងប្រកបដោយការទទួលខុសត្រូវខ្ពស់។

**អគ្គនាយក**

**ប៊ូ ថារិន**

សូមស្កេន QR ដើម្បីទាញយកសៀវភៅណែនាំអំពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការដាក់របាយការណ៍ហិរញ្ញវត្ថុ (សហគ្រាស)

សូមស្កេន QR ដើម្បីទទួលព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យនិងសវនកម្ម ឬសួរសំណួរមកកាន់ ន.គ.ស.